# ការសំភាសន៍របស់អ៊ុំស្រី មុំ ចាន់នី

កះ  អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ        ខះ  អ្នកដែរអោយគេសំភាសន៍ មុំ ចាន់នី

## <u>ការសង្ខេបប្រវត្តិរបស់ អ៊ុំស្រី មុំ ចាន់នី</u>

អ៊ុំស្រី មុំ ចាន់នី មានអាយុ55ឆ្នាំនៅក្នុងឆ្នាំ2018 អ៊ុំស្រី មុំ ចាន់នី មានភេទស្រី អ៊ុំស្រី មុំ ចាន់នី មានទីលំនៅបច្ចុប្បន្ននៅ ភូមិត្នោតជ្រុំ3 សង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ។

កះ  ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខះ  ចា៎!!

កះ  ដូចជាសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី26ខែ3 ឆ្នាំ2018 ហើយធ្វើនៅភូមិត្នោតជ្រុំមែនទេអ៊ុំ?

ខះ  ធ្វើនៅភូមិត្នោតជ្រុំ3

កះ  នៅភូមិត្នោតជ្រុំ3 ចុះឃុំអីគេដែរអ៊ុំមានដឹងឯអត់?

ខះ  ឃុំបឹងទំពុន

កៈ សង្កាត់បឹងទំពុនហើអ៊ុំ?
ខៈ នៅសង្កាត់បឹងទំពុន

កៈ នៅខ័ណ្ឌមានជ័យណាអ៊ុំ?

ខៈ ចា៎!!នៅខ័ណ្ឌមានជ័យនឹង

កៈ នៅរាជធានីភ្នំពេញនឹងណាអ៊ុំ?

ខៈ ចា៎!!នៅរាជធានីភ្នំពេញនឹងហាស

កៈ ចឹងសំរាប់ឈ្មោះពេញរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខៈ អាអូនសួរដល់នាមត្រកូលមែន?

កៈ បាទអ៊ុំបាទ?

ខៈ ខ្ញុំមានឈ្មោះមុំ ចាន់នី

កៈ អូ៎!!ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខៈ នៅខាងក្រៅនឹងគេហៅចាន់នីៗៗនឹង

កៈ ចុះកាលពីក្មេងនឹងមានមិត្តភក្តិរឺគេហៅអីផ្សេងទៀតទេអ៊ុំ?

ខៈ ហៅចឹងតែម្តងនឹងអូន

កៈ អូ៎!!ហៅចឹងតែម្តងនឹងហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះសព្វថ្ងៃអ៊ុំមានអាយុប៉ុន្មានដែរ?

ខៈ ខ្ញុំអាយុ55ឆ្នាំហើយអូន

កៈ ចឹងអ៊ុំអាយុ55ឆ្នាំមែនអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេ?

ខ៖ អត់ទេតារបស់ខ្ញុំនឹងបានចងចាំខ្ញុំអត់ចងចាំទេ

ក៖ ប៉ុន្តែថ្ងៃខែអ៊ុំអត់មានចងចាំដែរ?

ខ៖ ចា៎!!នឹងហើយខ្ញុំដឹងតែខ្ញុំកើតនៅថ្ងៃច័ន្ទ

ក៖ ចឹងអ៊ុំកើតថ្ងៃច័ន្ទណាអ៊ុំ ចុះឆ្នាំច័ន្ទគតិអ៊ុំឆ្នាំអីគេដែរអ៊ុំ ឆ្នាំជូត ឆ្លូវ ខាល ថោះហាសអ៊ុំ?

ខ៖ ខ្ញុំកើតឆ្នាំរោង

ក៖ ចឹងអ៊ុំឆ្នាំរោងណាអ៊ុំ ចឹងអ៊ុំកើតនៅឆ្នាំ1963?

ខ៖ ចា៎!!បែបនឹងហើយចឹង

ក៖ បាទអ៊ុំចឹងសំរាប់អ៊ុំកើតនៅណាដែរអ៊ុំ?

ខ៖ ខ្ញុំនៅកំពង់ចាមហោសអូន នៅឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម

ក៖ អូ៎!!បាទអ៊ុំប៉ុន្តែនៅភូមិអីគេដែរអ៊ុំ?

ខ៖ នៅភូមិម្សៀក

ក៖ ភូមិម្សៀកហោសអ៊ុំ?

ខ៖ ចា៎!!ប៉ុន្តែបើគេហៅក្នុងស្រុកវិញនឹងគេហៅភូមិមហាខ្ញូង ស្រុកកោះសូទិន ខេត្តកពង់ចាម

ក៖ បាទអ៊ុំបាទ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ខ្ញុំមានបងប្អូន5នាក់

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជាកូនរាមច្បងគេ

ក៖ អូ៎!!អ៊ុំកូនបងគេហោស?

ខ៖ ចា៎ៗ!!នឹងហើយ

ក៖ ចុះដូចជាមានស្រីប៉ុន្មាននាក់នឹងប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ មានស្រី4នាក់នឹងប្រុសម្នាក់

ក៖
អ៊ូ!!ចុះអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេថាប្អូនៗរបស់អ៊ុំមានឈ្មោះអីគេដែរចឹងហាស?

ខ៖ ប៉ុន្តែឥឡូវនឹងនៅតែ4នាក់ទេបានស្លាប់អស់មួយនាក់ហើយនឹង

ក៖ អ្នកស្លាប់នឹងជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ អ្នកដែរស្លាប់នឹងបន្ទាប់ទី4នឹង

ក៖ អ៊ូ!!បន្ទាប់ទី4ហោសអ៊ុំ?

ខ៖ ចា៎!!ទី5នឹងពៅគេនឹង

ក៖ បាទអ៊ុំ ចុះអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេ

ខ៖ បងប្អូនរបស់ខ្ញុំនឹងឈ្មោះប្អូនធី

ក៖ នឹងបន្ទាប់ពីអ៊ុំណាអ៊ុំ?

ខ៖ ចា៎!!ប្អូនរីបន្ទាប់ពីប្អូនរបស់ខ្ញុំអាប្រុសនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ប្អូនរឿន នឹងប្អូនឈឿន

ក៖ ចុះអ្នកដែរស្លាប់នឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ អ្នកដែរស្លាប់នឹងឈ្មោះប្អូនរី

ក៖ អ៊ូ!!បាទចុះកើតអីបានគាត់ស្លាប់ទេអ៊ុំ?

ខ៖ អាអូនអើយទៅនៅគេណោះ នៅគេហៅអីគេសេះសកកន្លែងដែរចាញ់គេហាស

ក៖ បាទអ៊ុំបាទ?

ខ៖ មានគ្រួសារទៅនឹងដល់ពេលនេះបែបចាញ់ផងអីផងក៏ស្លាប់នៅនឹងគេទៅ

កៈ បាទអ៊ុំ
ចុះអ៊ុំមានចងចាំថាកាលពីនៅក្មេងៗហាសអ៊ុំមានធ្លាប់បានលេងអីជាមួយបងប្អូនរបស់អ៊ុំទេ ដូចជាលេងបិទពួន លេងឡឹកបាយឡលេងអីផ្សេងៗមានដែរទេអ៊ុំ?

ខៈ ចា៎!!ធ្លាប់លេងបិទពួនចឹងទៅ
ប្រដេញគ្នាប៉ុន្តែខ្ញុំនឿយណាស់អូនអើយពីព្រោះចេះខ្ញុំស្លាប់ម៉ែហាស

កៈ បាទអ៊ុំចឹង?

ខៈ ស្លាប់ម៉ែតាំងពីខ្ញុំនៅអាយុ12ឆ្នាំមកម្ល៉េសនឹង

កៈ បាទចឹងអ៊ុំបាទ?

ខៈ ស្លាប់ដល់ពេលចឹងនៅតែឪពុកនឹងខ្ញុំនឹងក៏ការពារបងប្អូនរបស់ខ្ញុំនឹង
ប្អូនរបស់ខ្ញុំមីងពៅគេនឹងកើត មកបាន3ខ្ញុំដើរសុំគេអោយបៅ

កៈ បាទអ៊ុំបាទ?

ខៈ របៀបថានៅមុនជំនាន់អាពតនឹងទៀតហាសអូននឹងគេហៅចូលក្រុមហោស

កៈ គេចូលក្រុមអីគេវិញអ៊ុំ?

ខៈ ចូលក្រុមហើយបានចូលអាពតមកតែម្តងនឹងហោស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ចា៎!!នឹងហើយ

កៈ ប៉ុន្តែនៅជំនាន់លុនណុលតែម្តងនឹងហោសអ៊ុំ?

ខៈ
អូ៎ៗ!!ជំនាន់លុនណុលខ្ញុំកំសត់កំរណាស់អូនពីព្រោះម៉ែខ្ញុំស្លាប់បាត់ទៅខ្ញុំពិបាកជាងគេខ្ញុំនឿយ

កៈ ដោយសារតែអ៊ុំបងគេមែនទេអ៊ុំ?

ខៈ ខ្ញុំបងគេនៅមើលប្អូននៅតូចៗហោស

កៈ  បាទអ៊ុំបាទ?

ខៈ  ដើរសុំគេអោយបៅផងអីផងនឹង
នឹងនៅជំនាន់អាពតនឹងខ្ញុំដើរសុំគេអោយបៅនឹងហាស

កៈ  បាទអ៊ុំបាទ ចុះអ៊ុំគិតថាអ៊ុំធ្លាប់ទៅដើរលេងនៅស្រែជាមួយពួកគាត់អីដែរទេ?

ខៈ  ខ្ញុំឃ្វាលតែគោ ឃ្វាលអីនឹងអូន

កៈ  ជាមួយបងប្អូនរបស់អ៊ុំហោស?

ខៈ  ចា៎!!ជាមួយបងប្អូននឹងជាមួយយាយរបស់ខ្ញុំ ហើយខ្ញុំនៅតែជាមួយយាយរបស់ខ្ញុំទេ

កៈ  បាទអ៊ុំបាទនឹង?

ខៈ  ពីព្រោះម៉ែរបស់ខ្ញុំស្លាប់បាត់ទៅនឹង ខ្ញុំអត់មាននៅជាមួយឪពុកទេនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  ឪពុកទុកអោយប្អូនៗនឹងគេនៅទៅណាស់

កៈ  បាទអ៊ុំបាទចឹង?

ខៈ  គាត់មានប្រពន្ធចុងទៀតនឹង

កៈ  អូ៎!!ចឹងហោសអ៊ុំ?

ខៈ  ចា៎!!នឹងហើយ

កៈ  ចុះអ៊ុំចូលចិត្តលេងអីគេជាមួយប្អូនៗរបស់អ៊ុំទៅនឹង
កាលពីនៅក្មេងរឺមួយក៏ចូលចិត្តធ្វើការងារជាមួយប្អូនរបស់អ៊ុំ?

ខៈ  ខ្ញុំចូលចិត្តទេឃ្វាលគោឃ្វាលអីនឹង មានពួកម៉ាក់

កៈ  លេងសើចអីជាមួយពួកគាត់ចឹងទៅ?

ខៈ  ចា៎!!ពួកម៉ាក់ស្រីៗៗនឹងហាស ស្រីៗៗនៅជិតផ្ទះនឹងមានជីទួតមួយ ជីដូនមួយអីនឹង

កៈ  ចឹងមានចាប់ក្តាម ចាប់ត្រីអីនៅស្រែចឹងទៅណាអ៊ុំ?

ខ៖  ចា៎!!ទៅរកត្រីអីចឹងទៅ ទៅនៅបឹងហាស

ក៖  អូ៎!!បាទអ៊ំបាទ?

ខ៖  ចា៎!!ទៅអញ្ចាត់អីចឹងទៅណាស់អូន

ក៖  ទៅអញ្ចាត់ត្រីណាអ៊ំ?

ខ៖  ចា៎!!ហើយរួចពីនឹងមកនឹងខ្ញុំដើរកាប់អូសកាប់អីដុត
ភ្លើងស្ករនៅជាមួយម្ដាយមីងអីចឹងទៅណាស់

ក៖  បាទអ៊ំបាទនឹង?

ខ៖  កាប់អូសដុតស្ករ មានឃ្វាលគោឃ្វាលអីនឹងហាស

ក៖  បាទអ៊ំចុះដូចជាប្អូនៗរបស់អ៊ំនឹងសព្វថ្ងៃគាត់នៅណាដែរអ៊ំ?

ខ៖  អូននៅស្រុកហោស

ក៖  នៅស្រុកប៉ុន្តែពួកគាត់ធ្វើអីគេដែរអ៊ំ?

ខ៖  ឥឡូវនឹងគេមានកូនមានចៅអស់ហើយអូនអើយ

ក៖  ចឹងដូចជាគាត់ឈប់រកស៊ីហើយណាអ៊ំ?
ខ៖ ចា៎!!នឹងហើយ

ក៖  រឺមួយក៏គាត់ធ្វើការខ្លះនៅរកស៊ីខ្លះដែរអ៊ំ?

ខ៖  គាត់អ្នកខ្លះឡើងត្នោតណាស់អូនណាស់

ក៖  បាទអ៊ំបាទ?

ខ៖  នៅស្រុកខ្ញុំនឹងគេភាគច្រើនឡើងត្នោត

ក៖  អូ៎!!បាទអ៊ំបាទ?

ខ៖  អ្នកខ្លះទៅគេធ្វើចំការដូចជាគេដាំស្វាយដាំអីចឹងទៅណាស់

ក៖  បាទអ៊ំបាទ?

ខ៖ ចា៎!!នឹង

ក៖ ចុះដូចជាឪពុករបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំនឹងមានឈ្មោះមុំ

ក៖ មានឈ្មោះស្អីគេមុំដែរអ៊ុំ?

ខ៖ គាត់ឈ្មោះគ្រឹម មុំ

ក៖ អូ៎!!សព្វថ្ងៃនឹងអ៊ុំមានដឹងថាគាត់អាយុប៉ុន្មានដែរទេ?

ខ៖ គាត់ស្លាប់ហើយអូន

ក៖ ចឹងអ៊ុំអត់មានដឹងអាយុប៉ុន្មានទេណអ៊ុំ?

ខ៖ ចា៎!!អត់ដឹងទេ

ក៖ បាទចុះអ៊ុំ?

ខ៖ គាត់ស្លាប់យូរហើយតាគាត់ស្លាប់អាយុ50ឆ្នាំ

ក៖ ប៉ុន្តែគាត់ស្លាប់ប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖ មិនដឹងថាប៉ុន្មានឆ្នាំទេណនពុកស្លាប់ប៉ុន្មានឆ្នាំដែរទៅវាយូរដែរហើយនឹង

ក៖ អូ៎!!ចឹងហោសអ៊ុំចា៎!!ខ្ញុំអត់ចងចាំទេ?

ខ៖ ចា៎!!ខ្ញុំអត់ចងចាំទេ

ក៖ ចុះគាត់កើតនៅណាដែរអ៊ុំមានដឹងអត់ឪពុករបស់អ៊ុំហាស?

ខ៖ នេះគាត់កើតនៅស្រុកភូមិព្រះរាម នៅស្រុកបាទី នៅខេត្តតាកែវ

ក៖ អូ៎!!បាទចុះម្តាយរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំហោស?

ក៖ បាទម្តាយរបស់អ៊ុំហាស?

ខ៖ ដាក់នាមត្រកូលគាត់អត់?

កៈ បាទដាក់ទាំងអស់អុំ?

ខៈ គាត់មានឈ្មោះតោ មាស

កៈ គាត់មានឈ្មោះតោ មាស?

ខៈ តារបស់ខ្ញុំឈ្មោះតាតោ

កៈ ចឹងម្ដាយរបស់អុំមានឈ្មោះមាស?

ខៈ ចាំ!!ម្ដាយរបស់ខ្ញុំឈ្មោះមាស

កៈ អូ៎!!បាទគាត់ឈ្មោះប៉ុន្មានក៏អុំអត់មានដឹងដែរណាអុំ?

ខៈ ខ្ញុំអត់ចងចាំទេអូនអើយ

កៈ ចុះពួកគាត់កើតនៅណាដែរអុំ?

ខៈ គាត់កើតនៅ

កៈ នៅខ្វង មហាសៀកនឹងមែនអុំ?

ខៈ គាត់កើតនៅភូមិមហាខ្វង ស្រុកកោះសូទិន ខេត្តកំពង់ចាម

កៈ អូ៎!!បាទអុំបាទ?

ខៈ ចាំ!!ចឹងឯង

កៈ ចុះម្ដាយរបស់អុំកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអុំ ដូចជាគាត់នៅរស់ រឺមួយក៏គាត់ស្លាប់ហើយអុំ?

ខៈ គាត់ស្លាប់ហើយគាត់ស្លាប់អស់ហើយអូនអើយ

កៈ ប៉ុន្តែកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតនឹងចិញ្ចឹមគ្រួសារហាសអុំ?

ខៈ កាលពីគាត់នៅរស់នឹងគាត់ដូចជាគាត់ដាំស្ពៃ ឡើងត្នោតប៉ារបស់ខ្ញុំគាត់ជាអ្នកឡើងទេណាស់

កៈ បាទនឹងអុំ?

ខ៖  នឹងតាំងពីខ្ញុំដឹងក្តីមកខ្ញុំឃើញគាត់ដាំស្តែហើយនឹងឡើងត្នោត

ក៖  ឪពុករបស់អ៊ុំនឹងគាត់ឡើងត្នោត?

ខ៖  ចា៎!!ហើយក៏គាត់នឹងចិញ្ចឹមជ្រូកចិញ្ចឹមអីខ្លះដែរទៅណាស់អូន

ក៖  អូ៎!!បាទអ៊ុំ ចុះឪពុករបស់អ៊ុំនឹងគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖  ហ៊ីគាត់កាចដែរនឹងអូន

ក៖  ចុះម្តាយរបស់អ៊ុំ?

ខ៖  គាត់កាចដែរប៉ុន្តែគាត់ដឹងកាចគាត់ដឹងខុសដឹងត្រូវមិនមែនចេះតែវៃកូនផ្តេសផ្តាស់ទេ

ក៖  បាទចឹងអ៊ុំ?

ខ៖  បើកូនធ្វើអីខុសនឹងបានគាត់វៃ

ក៖  អូ៎!!បាទចុះម្តាយរបស់អ៊ុំនឹងគាត់កាចរឺមួយក៏ស្លូតដែរអ៊ុំ?

ខ៖  ម្តាយរបស់ខ្ញុំនឹងស្លូតណាស់

ក៖  អូ៎!!បាទអ៊ុំបាទ?

ខ៖  ម្តាយរបស់ខ្ញុំនឹងស្លូតណាស់

ក៖

ចុះអ៊ុំមានចងចាំកាលពីអ៊ុំនៅក្មេងៗកាលអ៊ុំនៅជាមួយពួកគាត់ហាសអ៊ុំធ្លាប់មានអនុស្សាវរីយ៍ អីជាមួយគ្នាដែរទេ ទៅស្រែរឺមួយក៏ធ្វើអីជាមួយឪពុកម្តាយរបស់អ៊ុំហាស?

ខ៖  អូនខ្ញុំដូចជាខ្ញុំមិនសូវបាននៅជាមួយគាត់ផងនឹង
ខ្ញុំច្រើននៅជាមួយយាយរបស់ខ្ញុំជាងនឹង

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖  ចា៎!!ពីព្រោះខ្ញុំបៅជាមួយយាយរបស់ខ្ញុំនឹង

ក៖  ចឹងមានន័យថាអ៊ុំនៅតែជាមួយយាយទេ?

ខ៖  ចា៎!!ខ្ញុំនៅតែជាមួយយាយទេនឹង

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ខ្ញុំមិនសូវបាននៅជាមួយម៉ែឪរបស់ខ្ញុំទេនឹង

កៈ ចឹងសំរាប់ឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំទេ?

ខៈ ប្រវត្តិគាត់នឹងខ្ញុំមិនសូវដឹងដែរ ពីព្រោះគាត់មានប្រពន្ធច្រើនណាស់

កៈ អូ៎!!បាទអ៊ុំចុះ?

ខៈ ចាំ!!ប្រពន្ធដើមគាត់នឹងនៅស្រុកគាត់ហោស

កៈ បាទអ៊ុំបាទៗៗ?

ខៈ ចាំ!!គាត់លែងប្រពន្ធដើមហើយនឹង

កៈ ហើយបានគាត់មកយកយាយ?

ខៈ បានគាត់មកយកម៉ែរបស់ខ្ញុំ

កៈ អូ៎!!បាទអ៊ុំ?

ខៈ មកយកម៉ែរបស់ខ្ញុំហើយដល់ពេលដែរគាត់ធ្វើការងារនៅពេទ្យកំពង់ចាមនឹង

កៈ បាទអ៊ុំបាទ?

ខៈ គាត់មានមីងខ្ញុំនឹងមួយហើយគាត់មានមួយទៀត

កៈ អូ៎!!គាត់យកប្រពន្ធច្រើនហោស?

ខៈ ចាំ!!គាត់ធ្វើការងារនៅពេទ្យនោះ

កៈ បាទអ៊ុំបាទ?

ខៈ ដល់ពេលចឹងគាត់ស្រលាញ់អ្នកដេកពេទ្យអីចឹងទៅណាស់

កៈ បាទអ៊ុំបាទចឹងហោស?

ខៈ គាត់ធ្វើការងារនៅពេទ្យនឹង ដូចថាអ្នកដែរដើរបើកថ្នាំអោយគេចឹងទៅ

កៈ ហើយគាត់ឃើញគេគាត់ចាប់អារម្មណ៍គេទៅ?

ខ៖ នឹងហើយ

ក៖ ចុះម្ដាយរបស់អ៊ុំគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខ៖ ដូចជាអត់ទេអូន

ក៖ អត់ទេណាអ៊ុំណា?

ខ៖ ពីព្រោះខ្ញុំមិនសូវយកចិត្តទុកដាក់ប៉ុន្តែបើសិនជាមួយយាយរបស់ខ្ញុំនឹងខ្ញុំ

ក៖ អ៊ុំដឹងច្រើនដែរ?

ខ៖ ខ្ញុំដឹងច្រើនដែរ

ក៖ អូ៎!!បាទអ៊ុំបាទចឹង?

ខ៖ ចុះម៉ែរបស់ខ្ញុំនឹងគាត់គ្រាន់តែជាអ្នកបង្កើតខ្លុះទេ
ប៉ុន្តែចិញ្ចឹមអីនៅលើយាយរបស់ខ្ញុំនេះនឹងហាស

ក៖ អូ៎!!ចឹងយាយជាអ្នកផ្គត់ផ្គង់ទៅ?

ខ៖ ចា៎!!យាយជាអ្នកផ្គត់ផ្គង់ទេច្រើនជាងនឹង

ក៖ បាទចុះយាយតាខាងម្ដាយនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ យាយតាខាងម្ដាយនឹងហោស?

ក៖ បាទអ៊ុំបាទគាត់មានឈ្មោះអីគេដែរ?

ខ៖ ចុះដូចដែរខ្ញុំប្រាប់ថាឈ្មោះតាតោ យាយប៉ុក

ក៖ នឹងយាយតាខាងម្ដាយហោស?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះយាយតាខាងឪពុកវិញអ៊ុំ?

ខ៖ យាយតាខាងឪពុកវិញនេះឪរបស់គាត់នេះ

ក៖ បាទប៉ុន្តែមានឈ្មោះអីគេដែរទៅអ៊ុំមានដឹងអត់?

ខ៖  បើជីតានឹងតាក្រឹម យាយទែម

ក៖  បាទអ៊ុំបាទ?

ខ៖  ហើយបើមកម៉ែក្មេករបស់ខ្ញុំម៉ែតារបស់ខ្ញុំនឹងហាស តាអៀង យាយខុត

ក៖  អូ៎!!បាទអ៊ុំបាទ?

ខ៖  ចា៎!!នឹងហើយចឹង

ក៖  ចុះយាយតាខាងម្ដាយគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖  គាត់កើតនៅស្រុកគាត់ណុង

ក៖  អូ៎!!បាទ ចុះយាយតាខាងឪពុកនឹងគាត់នៅណុងដែរ?

ខ៖  ចា៎!!នៅនឹង

ក៖  ចុះដូចជាអ៊ុំមកនៅទីក្រុងភ្នំពេញនឹងយូរនៅអ៊ុំ?

ខ៖  ខ្ញុំការហើយនឹងខ្ញុំមកនៅនេះនឹងហាសមកនៅភ្នំពេញនឹង

ក៖  ប្រហែលជាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖  ខ្ញុំឥឡូវនឹងខ្ញុំអាយុ55ឆ្នាំហើយនឹង បងជនខ្ញុំការមកនេះប៉ុន្មានឆ្នាំដែរហើយនឹង ការឆ្នាំ1982នឹង

ក៖  ចឹងការឆ្នាំ1982នឹងអ៊ុំមកនៅនឹងតែម្ដងហោសអ៊ុំ?

ខ៖  ខ្ញុំមកនៅបឹងត្របែកនឹង

ក៖  ចឹងវាអស់36ឆ្នាំអ៊ុំ?

ខ៖  ចា៎!!នឹងហើយ

ក៖  បាទអ៊ុំបាទ ចឹងសំរាប់អ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាមួយដែរទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖  អត់ទេអូនអើយ

កៈ ចឹងមានតែនៅស្រុកខ្មែរទេណអ៊ុំ?

ខៈ មានតែនៅស្រុកខ្មែរនឹង

កៈ អ៎ូ!!បាទអ៊ុំ ចុះស្វាមីរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះអៀង ចាន់ថន

កៈ បាទអ៊ុំបាទ ចុះ?

ខៈ នឹងឪពុករបស់គាត់ហាស

កៈ បាទចឹងហោសអ៊ុំ?

ខៈ គាត់មានឈ្មោះថាអៀង ចាន់ថន បើឈ្មោះគាត់តែម្តងនឹងឈ្មោះចាន់ថនៗនឹងហាស

កៈ ចុះសំរាប់អ៊ុំមានដឹងថាអ៊ុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេ?

ខៈ ខ្ញុំអត់ចងចាំទេប៉ុន្តែតារបស់ខ្ញុំនឹងបានចងចាំ

កៈ ប៉ុន្តែនៅឆ្នាំវិញណាដែរអ៊ុំដូចជានៅឆ្នាំ1982ហីអ៊ុំ?

ខៈ ចា៎!!

កៈ បាទអ៊ុំបាទ ចុះថ្ងៃខែអ៊ុំអត់មានចងចាំទេហោសអ៊ុំ?

ខៈ ណអត់មានចងចាំទេអូនអើយ

កៈ បាទចឹងអ៊ុំ
ចុះនៅពេលដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍នឹងដូចជាអ៊ុំជាអ្នករៀបចំដោយខ្លួនឯង
រឺមួយក៏ឪពុកម្តាយជាអ្នករៀបចមអោយដែរ?

ខៈ ម៉ែឪនឹងហាស

កៈ ចឹងម៉ែឪណអ៊ុំណ?

ខៈ ចា៎!!នឹងហើយខ្ញុំកាលពីជំនាន់ណុងខ្ញុំម៉ែទុកឪពុកដាក់ហើយណអូនណាស់

កៈ បាទអ៊ុំបាទនឹងហើយ?

ខ៖ មិនមែនដូចជាក្មេងៗៗសម័យឥឡូវនឹងទេ
កាលក្មេងៗៗជំនាន់ខ្ញុំទាល់តែម៉ែឪដូចថាម៉ែឪសួរថា

ក៖ បាទថាម៉េចទៅ?

ខ៖ អញ់អោយទៅគេហើយមិននៅលើអញ់ទៀតទេ
ចៅឯងមិនបាច់អីនេះទេប៉ុន្តែក្មេងសម័យឥឡូវនឹងមិនបាច់ទេណាស់

ក៖ បាទអ៊ុំបាទ?

ខ៖
ក្មេងសម័យឥឡូវនឹងទាល់តែក្មេងពីរនាក់នឹងស្រលាញ់គ្នាបានម៉ែឪតាមក្រោយនឹងហាស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ បើមួយជំនាន់ខ្ញុំនឹងអត់មានទេខ្ញុំគោរពម៉ែឪហាសម៉ែថាម៉េចខ្ញុំធ្វើចឹង

ក៖ បាទអ៊ុំ ចុះគិតថាតាពេលដែរចូលស្ដីដណ្ដឹងអ៊ុំនឹងដូចជាមានថ្លៃទឹកដោះទេ?

ខ៖ មានដែរតើ!!

ក៖ ប៉ុន្តែដូចជាពេលណុងប៉ុន្មានដែរអ៊ុំ?

ខ៖ ហេកាលណុងលុយថ្លៃណាស់អូនអើយ

ក៖ បាទអ៊ុំបាទ?

ខ៖ កាលណុងនៅចាយលុយមួយកាក់ពីរកាក់អីចឹងហាសណាស់

ក៖ ដូចជាពេលណាដែរអ៊ុំបានស្រលាញ់គ្នាជាមួយតា
ហើយរយះពេលប៉ុន្មានដែរគាត់មកចូលស្ដីដណ្ដឹង អ៊ុំចឹងហាស?

ខ៖ ខ្ញុំអត់ដែរស្គាល់ផងនឹង

ក៖ ចឹងអត់ដែរស្គាល់ទេណាអ៊ុំ?

ខ៖ ចា៎!!មិនដែរស្គាល់គ្នាទេ

ក៖ ប៉ុន្តែនឹង?

ខ៖ គាត់នឹងអោយម៉ែគាត់ជូនទៅ

ក៖ គាត់ចាប់អារម្មណ៍អ៊ុំ?

ខ៖ ពីព្រោះខ្ញុំហើយនឹងតារបស់ខ្ញុំនឹងយកជីដូនមួយនឹងជីដូនមួយនឹងហាស

ក៖ អូគេយកជីដូនមួយឯងនឹងហោស?

ខ៖ ចា៎!!ប៉ារបស់ខ្ញុំហើយនឹងម៉ែរបស់គាត់នឹងបងប្អូនបង្កើតនឹង

ក៖ អ៎ូ!!បាទអ៊ុំខ្វយល់ដែរអ៊ុំ?

ខ៖ ប្អូនរបស់ខ្ញុំបានគេស្គាល់នឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ខ្ញុំអត់ដែរស្គាល់ទេនឹងហាស

ក៖ បាទអ៊ុំបាទចឹង?

ខ៖ តារបស់ខ្ញុំនឹងចូលស្តីខ្ញុំនឹងអត់ដែរស្គាល់ខ្ញុំទេ

ក៖ ចុះសំរាប់អ៊ុំធ្លាប់បានរៀនខ្មែរដែរទេអ៊ុំ?

ខ៖ អូនអើយខ្ញុំរៀនបានតែបន្តិចទេទទួលជំនាន់នេះនឹងទៅ
បើនៅស្រុកខ្ញុំនឹងគេហៅជំនាន់អាមេរិន

ក៖ ជំនាន់អាមេរិន?

ខ៖ ជំនាន់អាមេរិនផង ជំនាន់លុនណុលផងនឹងហាស

ក៖ អ៎ូ!!នៅជំនាន់យាគកុងអីចឹងទៅ?

ខ៖ នឹងហើយ

ក៖ ប៉ុន្តែខ្ញុំចាំបានតិចៗៗទេណាស់?

ខ៖ ពីព្រោះនៅជំនាន់ណុងគេមិនធ្វើសង្គ្រាមអីចឹងទៅ ហើយបងប្អូនរបស់ខ្ញុំនឹងគេដឹកអង្ករ
គេហៅសាឡាងៗៗនៅជំនាន់យើងនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  គេធ្វើសង្គ្រាមនឹងហាស
ដល់ពេលដៃរបាញ់គ្នាហើយអាអង្ករនឹងអមេរិនគេនឹងហាសអូន

កៈ  បាទអ៊ុំបាទ?

ខៈ  ប៉ារបស់ខ្ញុំនឹងបានទៅយកអង្ករយកមកហូបចឹងទៅ

កៈ  បាទត្រូវហើយអ៊ុំ?

ខៈ  ពីព្រោះខ្ញុំនៅណោះស្រុកទន្លវាមិនមានកាណូតបើកចេញចូលនោះអី

កៈ  បាទអ៊ុំបាទត្រូវ?

ខៈ
ចា៎!!ដល់ពេលចឹងប៉ារបស់ខ្ញុំទៅយកអង្ករមកបានពីរប៉ាវតែអង្ករនឹងល្អៗណាស់អូនអើយ
ហើយរលូនតែម្តងនឹង

កៈ  ចុះគាត់យកមកពីណាវិញអ៊ុំ?

ខៈ  យកមកពីក្នុងអាមេរិននឹង គេធ្វើសង្គ្រាមហើយនឹងដល់ពេលនេះគ្មានដឹងយ៉ាងម៉េចទេ

កៈ  គេនៅសល់ហោសអ៊ុំ?
ខៈ  ចា៎!!នៅសល់នឹងហាស

កៈ  បាទអ៊ុំបាទ?

ខៈ
គេសល់អង្ករសល់អីនឹងហាសប៉ារបស់ខ្ញុំនឹងទៅលើបានពីរបេយកមកនឹងទៅទាំងយប់នឹង
លីបានពីរបេមកយើងដាំអង្ករនឹងស៊ីទៅ
ហើយអង្ករនឹងវាមានរលូនល្អណាស់វាអត់មានបាក់អីទេ

កៈ  បាទអ៊ុំបាទ?

ខៈ  នឹងជំនាន់ខ្ញុំនៅជាមួយប៉ារបស់ខ្ញុំ ដូចថាខ្ញុំមកធ្វើបន្លែនឹងដុតស្ករអីចឹងទៅណាស់

កៈ  បាទអ៊ុំបាទចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខ៖  អត់ចេះទេអូនអើយ

ក៖  ចឹងចេះតែខ្មែរទេណអ៊ុំ?

ខ៖  ពីព្រោះអត់បានរៀនផងវលិ

ក៖  ចុះកាលអ៊ុំរៀននឹងតើអ៊ុំរៀននៅណាដែរអ៊ុំ រៀនខ្មែរនឹងហាស?

ខ៖  ខ្ញុំរៀននៅស្រុកហោស

ក៖  ប៉ុន្តែសាលាឈ្មោះអីគេដែរអ៊ុំមានចងចាំទេ?

ខ៖  នឹងដូចខ្ញុំប្រាប់អូនឯងថាខ្ញុំនៅសាលាភូមិមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម នៅស្រុកខ្ញុំនឹងគេហៅថាវត្តម្សៀក នៅវត្តម្សៀកនឹង

ក៖  អូ៎!!នៅវត្តម្សៀកនឹងហោស?

ខ៖  ចា៎!!លាសាវត្តម្សៀកនឹងទៅកើតទៅ

ក៖  បាទអ៊ុំ ចុះបាទ?

ខ៖  ខ្ញុំរៀនបានតែបន្តិចទេអូន យើងអត់បានរៀនផងពីព្រោះបងប្អូនរញ៉េរញ៉ៃនឹងហាស

ក៖  បាទអ៊ុំបាទនឹង?

ខ៖  មិនសូវបានរៀនយកចិត្តទុកដាក់លែងតែមើលប្អូននឹង

ក៖  ត្រូវហើយអ៊ុំ
ចុះគិតថាកាលពីអ៊ុំនៅរៀននឹងអ៊ុំមានធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នា ហើយធ្លាប់ធ្វើអីគេខ្លះជាមួយគ្នាដែរចឹងហាសអ៊ុំ?

ខ៖  ខ្ញុំអត់សូវមានពួកម៉ាក់ទេមានតែបងប្អូនជីដូនមួយ
ជីទួតមួយនៅក្បែរផ្ទះនឹងតែពីរទៅបីនាក់នឹងហាស

ក៖  អូ៎!!ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ប៉ុន្តែវាស្លាប់ហើយវាប្អូនខ្ញុំនឹងប៉ុន្តែវាស្លាប់ហើយនឹងហាស

ក៖  ប៉ុន្តែអ៊ុំមានចងចាំឈ្មោះពួកគាត់ទេ?

ខ៖  នៅឈ្មោះវាឈ្មោះខ្នុក

កៈ គាត់ឈ្មោះខ្វក?

ខៈ ចា៎!!ឈ្មោះខ្វក ហើយមីង សារី ហើយឈ្មោះមី សុឃីម

កៈ
ប៉ុន្តែអ៊ុំមានចងចាំថាធ្លាប់មានអនុស្សាវរីយ៍អីគេខ្លះដែរជាមួយពួកគាត់កាលពីនៅក្មេងហាស
អ៊ុំ?
ខៈ អត់ទេខ្ញុំមិនសូវបានទំនាក់ទំនងជាមួយប៉ាវាទេ
ខ្ញុំទំនាក់ទំនងជាមួយតែកូននឹងពីព្រោះយប់ៗ ធ្លាប់ដើរលេងជាមួយគ្នា
ហើយទិញអីៗស៊ីចឹងទៅ ហើយក៏លេងបិទពួនអីចឹងទៅណាស់

កៈ បាទអ៊ុំបាទ?

ខៈ ចា៎!!ចឹងឯង

កៈ បាទ ចុះអ៊ុំគិតថាអ៊ុំធ្លាប់ទៅធ្វើការងារនៅវាលស្រែទេអ៊ុំ?

ខៈ ចា៎!!ធ្លាប់ដែរតើ!!

កៈ អ៊ុំធ្វើអីគេដែរនៅវាលស្រែអ៊ុំ?

ខៈ ខ្ញុំទៅស្រែនឹងខ្ញុំទៅជាមួយតានឹងខ្ញុំស្ទូង ហើយក៏ខ្ញុំដាំបាយអីចឹងទៅ
នឹងឃ្វាលគោអីចឹងទៅ

កៈ បាទអ៊ុំបាទចឹង?

ខៈ ពេលម៉ោង4អីនឹងខ្ញុំបានបកមកផ្ទះវិញហើយដឹកគោមកផ្ទះវិញហើយនឹងហាស

កៈ បាទអ៊ុំបាទ?

ខៈ ចា៎!!វាចឹងនឹងហើយ

កៈ ចុះអ៊ុំគិតថាអ៊ុំធ្វើការងារអីគេខ្លះដែរតាំងពីក្មេងរហូតមកដល់ពេលនេះដែរអ៊ុំ?

ខៈ តាំងពីក្មេងនឹងខ្ញុំពុះអូស រកអូសពុះអូសដុតភ្លើងស្ករ

កៈ បាទអ៊ុំបាទចឹង?

ខ៖ រួចពីដុតភ្លើងស្ករចឹងទៅខ្ញុំរែកទឹកចឹងដាក់ពាង

ក៖ មួយនឹងយើងធ្វើអោយគេរឺមួយក៏យើងធ្វើអោយក្រុមគ្រួសាររបស់យើងដែរអ៊ុំ?

ខ៖ អត់ទេយើងធ្វើនៅផ្ទះយើងតែម្តងនឹងហាស

ក៖ អូ!!បាទអ៊ុំបាទ?

ខ៖ ចា៎!!នឹងហើយចឹងពីព្រោះទន្លេវានៅឆ្ងាយពីផ្ទះហោស

ក៖ ដល់ចឹងទៅរែកម៉ាល្ងាចនឹងបានបីទៅបួនរែកហើយមកដាក់ក្នុងពាងហាសអូន

ក៖ បាទអ៊ុំត្រូវហើយចឹង?

ខ៖ ចា៎!!នឹងចឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់បើកអាជីវកម្មលក់ដូរអីទេអ៊ុំ?

ខ៖ ដូចជាអត់ទេអូន

ក៖ ចឹងអត់ទេណាអ៊ុំណា?

ខ៖ ចា៎!!អត់មានទេ

ក៖ ប៉ុន្តែសំរាប់អ៊ុំគិតថាអ៊ុំធ្លាប់ចិញ្ចឹមសត្វដែរទេអ៊ុំ?

ខ៖ បើមកពីជំនាន់ខ្ញុំមកនៅបឹងត្របែកនឹងអានឹងខ្ញុំលក់ដូរ

ក៖ អូ!!អ៊ុំលក់អីគេដែរអ៊ុំ?

ខ៖ ខ្ញុំលក់ចាប់ហួយហោស

ក៖ អូ!!អ៊ុំលក់ចាប់ហួយហោសអ៊ុំ?
ខ៖ ចា៎!!នឹងហើយចឹង

ក៖ ចុះអ៊ុំធ្លាប់ចិញ្ចឹមសត្វទេអ៊ុំ?

ខ៖ ខ្ញុំចិញ្ចឹមជ្រូកអូន

ក៖ ចឹងអ៊ុំចិញ្ចឹមជ្រូកហោសអ៊ុំ?

ខ៖  ខ្ញុំលក់ខ្លះដែរមុនដំបូងលក់មាន់ អស់ពីលក់មាន់ចឹងទៅខ្ញុំលក់មឹក ចុះបើយើងអត់ចឹងយើងចេះតែ ដើរស្វែងរកទៅណាស់អូនណាស់

ក៖  បាទអ៊ុំបាទ?

ខ៖  ដើររកស្វែងរកលក់ទៅនឹងហាស

ក៖  ចុះតែលក់នេះលក់នោះហើយណាអ៊ុំ?
ខ៖  ចា៎!!លក់នេះលក់នោះលក់ត្រីកាម៉ុងត្រីអីចឹងទៅ

ក៖  អូ៎!!បាទអ៊ុំបាទ?

ខ៖  អោយបានរួចមួយហូបៗចឹងទៅណាស់

ក៖  ចឹងអ៊ុំចិញ្ចឹមតែជ្រូកទេអ៊ុំអត់មានចិញ្ចឹមមាន់ទេអីទេណាអ៊ុំ?
ខ៖  ចិញ្ចឹមមកនេះបានខ្ញុំចិញ្ចឹមនៅនោះខ្ញុំចិញ្ចឹមជ្រូក

ក៖  គោអីអ៊ុំអត់មានចិញ្ចឹមទេណាអ៊ុំ?
ខ៖  គោអត់មានទេ មើលខ្ញុំចិញ្ចឹមជ្រូក ចិញ្ចឹមទាស៊ីជាមួយបាយជ្រូកនឹងទៅ

ក៖  បាទអ៊ុំបាទនឹង?

ខ៖  ចា៎!!ហើយចិញ្ចឹមមាន់ខ្លះដែរទៅ

ក៖  អូ៎!!ចឹងហោសអ៊ុំ?
ខ៖  នឹងកាលណុងខ្ញុំនៅបឹងត្របែកហាស

ក៖  បាទអ៊ុំបាទ?

ខ៖  ហើយបើមកនៅនេះខ្ញុំចិញ្ចឹមមាន់ ហើយខ្ញុំលក់ចាប់ហ្វួយដែរប៉ុន្តែខ្ញុំឈឺជើងខ្ញុំចឹងទៅ ខ្ញុំក៏លែងលក់លែងអីខ្ញុំហើយនឹង

ក៖  អូ៎!!ចឹងអ៊ុំសំរាកហើយណាអ៊ុំ?
ខ៖  ចា៎!!ខ្ញុំសំរាកហើយតាំងពីការកូនរបស់ខ្ញុំអាមួយពៅមកនឹងខ្ញុំឈឺជើងឈឺអីចឹងទៅ
មុនលេងបាល់លេងអីនៅនឹង
ដល់ឥឡូវនឹងលេងបាល់ទៅតាំងពីភ្នំលែងមានមនុស្សលែងមានអីទៅ
វាស្ងាត់ឈឹងចឹងទៅខ្ញុំក៏លែងលក់ចឹងទៅណាស់

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ខ្ញុំលក់ស្រាលក់អីចឹងទៅណាស់

កៈ បាទចឹងហោស?

ខៈ ខ្ញុំលក់គ្រប់មុខនឹងដល់ពេលដែរស្ងាត់មនុស្សស្ងាត់អីចឹងទៅខ្ញុំឈប់លក់ទៅ

កៈ បាទចឹងបាទ?

ខៈ ហើយមួយទៀតនឹងខ្ញុំឈឺជើងផងនឹង

កៈ
ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ
?

ខៈ ដូចជាឥឡូវនឹងកូនចិញ្ចឹមវិញនឹងអូន

កៈ អូ៎!!ចឹងទេហោសអ៊ុំ?
ខៈ ចា៎!!នៅធ្វើបាយទឹកអោយចៅហូបចឹងទៅ កូនចិញ្ចឹមវិញនឹង

កៈ ចុះអ៊ុំគិតថាកាលពីនឹងឥឡូវនឹងទាំងជីវភាព នឹងទាំងសុខភាពនឹងយ៉ាងម៉េចដែរអ៊ុំ?

ខៈ
ចេះអូនកាលពីតារបស់ខ្ញុំហើយនឹងកូនរបស់ខ្ញុំនៅបើកឡានដូចថាយើងរកនៅដៃនៅជើងចឹ
ងហាស

កៈ បាទអ៊ុំបាទ?

ខៈ វាគ្រាន់តែថាបានមួយចាយអីដែរចឹងហាសអ៊ុំ?

កៈ បាទអ៊ុំបាទ?

ខៈ ហើយដល់ឡាននឹងខ្ញុំលក់អស់ហើយនឹងឡានពីរលក់ទាំងពីរនឹងហាស

កៈ បាទអ៊ុំបាទ?

ខ៖
មានឡានបីប៉ុន្តែកូនរបស់ខ្ញុំនឹងវាចូលធ្វើការងារនៅអគ្គីសនីមួយចឹងទៅកូនរបស់ខ្ញុំលក់ឡាន ដែរនឹងហាស វាទិញឡានតូចនឹងហាសកូនប្រសាររបស់ខ្ញុំនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖
ចាំ!!ទិញឡានតូចនៅរាល់ថ្ងៃនឹងហាសដល់ពេលចឹងវាចូលធ្វើការងារនៅអគ្គីសនីទៅនឹងខ្ញុំក៏លក់ដែរប៉ុន្តែខូចហាសឡានហាសតិចខូចៗអូនអើយ

ក៖ ឡានចាស់ណាអ៊ុំណា?

ខ៖ ចាំ!!អើរចុះបើយើងមកនឹងវារៀងចាស់ពីគេមកដែរនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ តិចខូចៗហើយនឹងហាសដល់ពេលចឹងវាខ្វះខាតលុយមិនត្រូវខ្ចីលុយអង្គការចឹង

ក៖ បាទអ៊ុំបាទ?

ខ៖ ខ្ចីលុយអង្គការចឹងទៅយកមកសងយកមកធ្វើផងនឹងស៊ីខ្លះអីខ្លះចឹងទៅណាស់អូន

ក៖ អូចឹងហោសអ៊ុំ?

ខ៖ ដល់ចឹងខ្ញុំលក់ឡានអោយអស់នឹងហាសក៏យកទៅសងគេអស់ចឹងទៅណាស់

ក៖ បាទអ៊ុំគិតថាម្ហូបអីគេដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ?

ខ៖ ពិបាកណាស់អូនម្ហូបអើរមានតែស្លម្ជូរ ស្ងោរ ចូលចិត្តដូចថាចិញ្ច្រាំផ្អកអីចឹងទៅ

ក៖ អូ!!បាទអ៊ុំបាទ?

ខ៖ ចាំ!!ផ្អកសាច់ជ្រូកអីចឹងទៅណាស់ ចិញ្ច្រាំត្រីប្រម៉ាចិញ្ច្រាំសាច់ជ្រូកអីដែរចឹងនឹង

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ដល់ឥឡូវនឹងប្រែប្រួលហើយអូនអើយ

ក៖ បាទចឹង?

ខ៖ ល្មមៗៗនឹងអត់ហូបទេនឹងដូចថាវាហូបអត់ឆ្ងាញ់ហាស

ក៖ បាទត្រូវហើយអ៊ុំ?

ខ៖ មានការប្រែប្រួលនឹងដូចថាស៊ីនេះមិនឆ្ងាញ់ស៊ីនោះមិនឆ្ងាញ់មិនមែនដូចពីមុនណា ពីមុនអីក៏ឆ្ងាញ់ៗៗដែរឥឡូវនឹងអត់ទេ

ក៖ បាទអ៊ុំចុះអ៊ុំគិតថាល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងតាំងពីក្មេងហាសអ៊ុំ?

ខ៖ ចូលចិត្តទាញព្រាតចឹងទៅ រាំវង្សអីចឹងទៅណាស់

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ បោះអង្គុញអីចឹងទៅ

ក៖ លាក់កន្សែង នឹងបោះអង្គុញហើយណាអ៊ុំ?
ខ៖ ចាំ!!លាក់កន្សែងចឹងទៅ
ហើយមកប៉ុន្តែជំនាន់ខ្ញុំគេច្រើនតែនេះអូនគេជិះកង់ចឹងទៅជិះកង់មួយ
ចឹងទៅមានផាងចេកហាស

ក៖ បាទអ៊ុំបាទ?

ខ៖
គេច្រើនយកផាងចេកនឹងធ្វងមួយម៉ែត្រចឹងទៅជិះកង់កាន់ផាងចេកទុកវៃគ្នាទៅវិញទៅមក អីចឹង ទៅណាស់

ក៖ អូ៎!ហ្វគេលេងចឹង?

ខ៖ កាលពីជំនាន់ខ្ញុំហាស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ជំនាន់ឥឡូវនឹងគេច្រើនបាតម្សៅ

ក៖ បាទអ៊ុំត្រូវហើយអ៊ុំ?
ខ៖ នឹងហើយខ្ញុំដឹងខ្ញុំធ្លាប់លេងចឹងអូន

ក៖ បាទអ៊ុំ ចុះអ៊ុំគិតថាអ៊ុំចេះច្រៀងដែរទេអ៊ុំ?

ខ៖ អត់អត់ចេះទេ

ក៖ ចុះអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរទេអ៊ុំ?

ខ៖ ចាំ!!ខ្ញុំចូលចិត្តដែរតើ!!

ក៖ លក្ខណះបទសម័យរឺមួយបទបុរាណដែរអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តបទពីដើមៗៗនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ អើរប៉ែនរ៉ន ស៊ិនស៊ីសាម៉ុតនឹងអីហាស

ក៖ រស់សារីសុជាអីនឹង?

ខ៖ ចាំ!!សុរីសុជានឹងខ្ញុំអត់សូវចូលចិត្តទេ

ក៖
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខ៖ ផ្ទះរបស់ខ្ញុំហោស?

ក៖ បាទពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាសអ៊ុំ
ផ្ទះលក្ខណះបែបជាឈើរឺមួយក៏ថ្មចឹងហាសអ៊ុំ?

ខ៖ ចាំ!!ពីមុនមកនៅបឹងត្របែកណោះនៅផ្សារដើមថ្កូវណោះនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ អានឹងផ្ទះឈើអូនផ្ទះឈើនឹង

ក៖ ដល់ពេលឥឡូវនឹង?

ខ៖ ដល់ពេលដែរខ្ញុំលក់ពីណុងមកខ្ញុំបានធ្វើផ្ទះថ្មនេះ

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ចាំ!!នឹងចឹង

កៈ អូ៎!!បាទ តែផ្ទះមួយនឹងនរណាគេជាអ្នកសាងសងវាដែរអ៊ុំ ដូចជាអ៊ុំជួលគេធ្វើរឺមួយក៏ក្រុមគ្រួសាររបស់អ៊ុំចេះធ្វើផ្ទះដែរអ៊ុំ?

ខៈ ខ្ញុំជួលគេធ្វើហាសអូន

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ នឹងវាចឹង

កៈ ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងគេធ្វើគេប្រើឧបករណ៍អីសំរាប់ធ្វើដែរទេអ៊ុំ?

ខៈ អើរនឹងយើងមានតែទិញដែកទិញ ស៊ីម៉ង់ ខ្សាច់កាលណុងចឹងខ្ញុំមានឡានខ្លួនខ្ញុំនឹងខ្ញុំ

កៈ ទៅដឹកខ្លួនឯងទៅណាអ៊ុំ?

ខៈ ចា៎!!ដឹកខ្សាច់ដឹកថ្មអីចឹងទៅ ដាក់ក្នុងផ្ទះខ្លួនយើងចឹងហាស

កៈ បាទអ៊ុំត្រូវហើយអ៊ុំ?

ខៈ ហើយដឹកថ្មអីចឹងទៅ ខ្សាច់អីចឹងទៅ ស៊ីម៉ង់អីចឹងទៅយើងជួលតែជាងទេ

កៈ បាទអ៊ុំបាទ?

ខៈ ជួលជាងដូចថាជាងគេយកតំលៃប៉ុន្មានយកតំលៃប៉ុន្មានអីចឹងហាស

កៈ បាទចុះអ៊ុំគិតថា?

ខៈ សំភារៈលើយើងហាសអូន

កៈ

ចុះអ៊ុំគិតថាជំនាញអីដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំលក់ដូររឺមួយក៏ធ្វើអីគេមួយដែរចឹងហាស?

ខៈ ខ្ញុំចេះតែលក់ដូរទេអូនអើយ

កៈ

ចុះឪពុកម្តាយរបស់អ៊ុំនឹងគាត់ធ្លាប់បានបង្រៀនពីជំនាញអីផ្សេងទៅអ៊ុំទេដូចជាលក្ខណៈថា វេញវល្លិ៍ កូរស្ករត្នោត ធ្វើផ្តៅចឹងទៅ?

ខៈ អត់អត់ចេះធ្វើផ្តៅទេ

កៈ អូ៎!!អ៊ុំអត់ចេះទេ?

ខៈ មានតែកូនស្ដុរនឹង

កៈ ចឹងកូរស្ដុរអ៊ុំចេះណាអ៊ុំ?

ខៈ ចា៎!!នឹងចេះកូរស្ដុរនឹងបានជាខ្ញុំចេះ

កៈ ចុះមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខៈ មានតែជីដូនមួយខ្ញុំនៅកំពង់ចាមហោសអូនអើយ

កៈ គាត់ចេះលេងភ្លេងអីគេដែរអ៊ុំ?
ខៈ ចា៎!!គេចេះលេងភ្លេងសៀម

កៈ គាត់ចេះលេងភ្លេងសៀមណាអ៊ុំ?

ខៈ ចា៎!!នឹងហើយចឹង

កៈ ចុះអ៊ុំអាចប្រាប់ពីពេលលំបាករបស់អ៊ុំបន្ដិចបានទេអ៊ុំ ដូចថាអ៊ុំធ្លាប់ជួបកាលលំបាកអីគេខ្លះដែរចឹងហាសអ៊ុំ?

ខៈ
អើរដូចខ្ញុំប្រាប់អូនឯងថាខ្ញុំពីមុនមកនឹងមិនសូវបានរៀនបានអីនឹងមកពីម្ដាយស្លាប់នឹងហើយប្អូននឹង ហាសកើតមកបានបីខែខ្ញុំដើរសុំអោយបៅចឹងទៅ
មកដល់ប្អូនរៀងនេះបន្ដិចនឹងដល់ពេលដែរយាយខ្ញុំនឹង
គាត់រកគេកាយសរសៃអីចឹងទៅកាលណុងគាត់មានទាន់ចាស់អីណាម៉ានទេគាត់នៅរៀងនេះដែរនឹងហាស

កៈ បាទអ៊ុំបាទ?

ខៈ មកកាយសរសៃអីចឹងទៅចេញទឹកដោះទៅបានអោយបៅនឹងយាយរបស់ខ្ញុំនឹងទៅ

កៈ អូ៎!!នឹងកាលបីនៅក្មេងចុះកាលពីជំនាន់ពលពតអ៊ុំធ្លាប់ជួបទុកលំបាកអីគេដែរទៅអ៊ុំ?

ខៈ ជំនាន់ពលពតនឹងខ្ញុំធ្លាប់ចុះគេតាមក្រុមហាសអូនណាស់

កៈ បាទអ៊ុំបាទ?

ខ៖
ចាំ!!ខ្ញុំធ្លាប់កៀអាចម៍គោធ្លាប់គេប្រជុំចឹងទៅដូចថាយើងក្រោកមិនទាន់គេចឹងទៅគេប្រជុំគេតិចទៀន អោយយើងចឹងទៅណាស់

ក៖ បាទអុំបាទ?

ខ៖ តិចទៀនអោយយើងចឹងទៅថាម៉េចបានយើងដើបមិនទាន់គេលើកអាចម៍គោអីចឹងគេមានរទេះមួយអូន

ក៖ បាទបាទនឹង?

ខ៖
ដូចថាមួយក្រុមនឹងមានប៉ុន្មាននាក់មាន10នាក់ចឹងដូចថាខ្លះគេបានទៅៗខ្ញុំអត់បានទៅចឹងទៅ បានទៅតែពីរទៅបីនាក់ចឹងទៅ

ក៖ បាទអុំបាទ?

ខ៖ ប៉ុន្មាននាក់នឹងគេបានទៅដល់ពេលដែរគេប្រជុំគេតិចទៀនអោយយើងចឹងទៅ

ក៖ គេថាអោយយើងហោសអុំ?

ខ៖
ចាំ!!គេស្តីអោយយើងចឹងទៅថាឈ្មោះនេះៗអត់បានមកធ្វើការងារអីចឹងទៅណាស់អូន

ក៖ ចុះគេអត់មានថាអីគេអត់មានយកទៅណាអីណាហីអុំ?

ខ៖ អត់មានយកទៅណាទេ ហើយដល់មកខ្ញុំរៀងនេះបន្តិចនឹង
គេហៅខ្ញុំជាកងនារីហើយណាស់

ក៖ បាទអុំបាទ?

ខ៖ គេហៅកងនារីនឹងគេចញ្ជូលខ្ញុំទៅកងនារីចឹងទៅគេហៅយកទៅវែកដី
អើរវែកដីចឹងមានស្រីប្រុស មួយគូរៗចឹងទៅណាស់

ក៖ បាទអុំបាទ?

ខ៖ ប៉ុន្តែអត់ចេះស្រលាញ់គ្នាអីទេគ្រាន់តែគេអ្នកកាប់យើងអ្នកវែក

កៈ អូ៎!!គេធ្វើចឹង?

ខៈ ជួនកាលពេលខ្លះយើងអ្នកកាប់គេអ្នកវែកចឹងហាស

កៈ បាទពេលណុងអ៊ុំនៅណាដែរទៅ?

ខៈ ខ្ញុំនៅស្រុកហោស

កៈ អ៊ុំនៅកំពង់ចាមហោស?

ខៈ ចា៎!!នៅកំពង់ចាមនឹងហាស

កៈ ចុះរបបអាហារម៉េចដែរអ៊ុំ?

ខៈ
មានអីអូនគេស្លអោយយើងបបរចឹងទៅដូចថាអើរវាមិនស្វរបានខាប់បានអីចឹងទៅមួយវែកពីរវែកចឹង
ទៅដូចថាពីរវែកទៅបីវែកចឹងទៅសំរឹតទៅបានចឹងបានមួយវែកជាងអីចឹងទៅកាកហាស

កៈ បាទអ៊ុំបាទចឹង?

ខៈ ចា៎!!នឹងវាចឹង

កៈ ចុះអ៊ុំគិតថាពេលដែរដាច់ពលពតនឹងអ៊ុំមានធ្លាបើជួបទុកលំបាកអីទៀតទេអ៊ុំ?
ខៈ ដាច់ពលពតនឹងអើរខ្ញុំដាច់ពលពតហើយនឹង

កៈ អ៊ុំចាប់ផ្ដើមរកស៊ីហើយណាអ៊ុំ?

ខៈ ខ្ញុំការនឹងបែកអាពតហើយនឹងខ្ញុំការនឹង

កៈ អូ៎!!បាទអ៊ុំ?

ខៈ ចា៎!!ខ្ញុំការនឹងហើយនឹងមកនៅជាមួយគាត់នេះនឹង
នៅភ្នំពេញបានប៉ុន្មាននេះនឹងខ្ញុំទៅនៅស្រុកគាត់ នឹងហាស

កៈ នៅតាកែវ?

ខ៖
នៅតាកែវនឹងនៅជាមួយម៉ែក្មេកនឹងដូចថាខ្ញុំស្ទូងខ្លះចឹងទៅនៅស្រុកណុងគេច្រើនស្ទូងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ខ្ញុំស្ទូងខ្លះចឹងទៅ ខ្ញុំត្បាញហូលខ្លះចឹងទៅ

ក៖ បាទអ៊ុំបាទ?

ខ៖ ដល់ជំនាន់ចាប់ពីជំនាន់នេះនឹងម៉ែក្មេករបស់ខ្ញុំនឹងអោយខ្ញុំមកនៅភ្នំពេញវិញមកនឹងមកនៅភ្នំពេញមកនៅជាមួយបងថ្លៃនឹងហាស

ក៖ មកធ្វើអីគេដែរអ៊ុំពេលណុង?

ខ៖ ជំនាន់ណុងតារបស់ខ្ញុំនឹងគាត់រកស៊ីប្រេងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ រកស៊ីប្រេងខ្មៅ ហើយតារបស់ខ្ញុំនឹងគាត់រត់ស៊ីខ្លូផងនឹងរត់កង់ឌុបផងនឹងហាស

ក៖ គាត់ធ្វើការងារច្រើនកន្លែងណាអ៊ុំ?
ខ៖ ចាំ!!សំរាប់ចិញ្ចឹមជីវិតនឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ?
ខ៖ រៀបរាប់នឹងចុះយើងដូចថាកើតមកជាកូនអ្នកក្របាសអូនពិបាកហាស

ក៖
បាទអ៊ុំបាទចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់អ៊ុំដែរទៅ?

ខ៖ ឆាកជីវិតនឹងដល់មកមានគ្រួសារចឹងទៅ គ្រួសាររបស់ខ្ញុំនឹងគាត់សប្បាយជាងខ្ញុំ

ក៖ ម៉េចចឹងអ៊ុំ?

ខ៖ គាត់ច្រើនតែដើរចឹងអីចឹងទៅខ្ញុំច្រើនការពារកូនចៅមើលផ្ទះមើលអីចឹងទៅ

ក៖ បាទអ៊ុំបាទចឹង?

ខ៖ ចាំ!!នឹងវាចឹង

ក៖
ចុះអ៊ុំធ្លាប់គិតថាកាលពីក្មេងអ៊ុំធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអីគេដែរទេ?

ខ៖ ដូចជាអត់មានទេអូន

ក៖
ចុះកាលពីអ៊ុំនៅរៀននឹងអ៊ុំធ្លាប់មានគិតថាអ៊ុំចង់ធ្វើជាប៉ូលីសរឺមួយក៏ចង់ធ្វើជាទាហ៊ានអីដែរទេអ៊ុំ?

ខ៖ អត់ចង់សោះប៉ូលីសទាហ៊ាននឹង

ក៖ សូម្បីតែគ្រូពេទ្យ គ្រូបង្រៀនអីនឹងក៏អត់ចង់ដែរណាអ៊ុំ?
ខ៖ អត់ចង់ទាល់តែសោះនឹង

ក៖ អូ៎!!បាទអ៊ុំបាទ
ចុះបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងតើអ៊ុំចង់ផ្តែផ្តាំអីទៅគាត់ដែរអ៊ុំ?

ខ៖ ចង់ផ្តែផ្តាំថាអោយរាល់ថ្ងៃនឹងអោយចៅនឹង ខំរៀនទៅយកចិត្តទុកដាក់ យើងចេះទៅវាស្រួលហាស ណាអូនណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ គេធ្វើការងារគេរកអ្នកដែរចេះអ្នកដែរដឹង គេមិនរកអ្នកដែរងងឹតទេ ល្ងង់នឹងក៏គេមិនចង់បានដែរអូនអើយ

ក៖ អូ៎!!បាទអ៊ុំបាទ?
ខ៖ រាល់ថ្ងៃនឹងចឹងចា គេចេះទៅគេមានចំណេះវិជ្ជាទៅគេសរសេរតែបន្តិចនឹង

ក៖ អូ៎!!គេបានលុយស្រួលណាអ៊ុំ?

ខ៖ ចាំ!!បានលុយទិញកាហ្វេទិញអីនឹងហាស

ក៖ អូ៎!!ចឹងណាអ៊ុំ?

ខ៖ ដល់ពេលដែរល្ងង់នឹងយើងរកស៊ីដោយកំលាំងពិបាកណាស់អូនអើយ

ក៖ បាទអ៊ុំបាទចុះ?

ខ៖ វានឿយហត់ណាស់

ក៖ ចុះបើសិនជាអ៊ុំចង់អោយកូនចៅលក្ខណះជៀសវៀងវិញហាស
តើអ៊ុំចង់អោយពួកគាត់ជៀសវៀងអីគេដែរអ៊ុំ?

ខ៖ ចង់អោយវាជៀសវៀងប៉ុន្តែចៅរបស់ខ្ញុំនឹងស្រីទេទៅរៀនរាល់តែថ្ងៃនឹងហោស

ក៖ បាទអ៊ុំបាទ?

ខ៖ ទៅរៀនរាល់តែថ្ងៃនឹងហាសមានចៅស្រីមួយនឹងប្រុសមួយ
ហើយមួយទៀតនឹងចៅដែរគ្រាន់តែវា លែងគ្នាចឹងទៅខ្ញុំពិបាកណាស់
វាលែងគ្នាចឹងទៅវានៅខាងយាយណោះវាបន្តិចចឹងទៅ ហើយមកខ្ញុំនេះបន្តិចចឹងទៅ
ហើយវាលែងគ្នាចឹងទៅចៅស្រីនឹងត្រូវបានមកខ្ញុំដល់ពេលនេះទៅឃុំ សង្កាត់អីចឹងទៅ

ក៖ បាទអ៊ុំបាទ?

ខ៖
ហើយកូនរបស់ខ្ញុំអាមួយប្រុសនឹងវាថាម៉ែអើយអោយទៅវាចឹងទៅកុំអោយវាបាក់បែកម៉ែវា
អីនឹង

ក៖ បាទត្រូវហើយអ៊ុំ?

ខ៖
ដល់ពេលចឹងសង្កាត់នឹងគេប្រាប់ម៉ែចឹងថាអោយជួយចិញ្ចឹមគ្នាទៅល្មមអាយុ18ឆ្នាំហាស

ក៖ បាទត្រូវហើយអ៊ុំ?

ខ៖ ជួយចិញ្ចឹមគ្នាទៅទំរាំធំនឹងបានទៅគេនោះទេមិនមែនបានមកខ្ញុំទេណាស់អូន

ក៖ អូ៎!!ចឹងហោស?

ខ៖ ចា៎!!ពីព្រោះកូនរបស់ខ្ញុំនឹងអោយទៅគេហើយនឹង

ក៖ ចឹងមានអីចង់ផ្តែផ្តាំផ្សេងទៀតទេអ៊ុំ?

ខ៖ ដូចជាអត់មានអីទៀតទេអូនអើយ ដូចជាអត់ចេះទេហាស

ក៖ បាទអូអ៊ុំអត់ចេះទេបានច្រើន ល្មមនឹងចេះទៀត?

ខ៖ អើរអូនឯងសួរចឹងចេះតែឆ្លើយតាមចឹងទៅ

ក៖
បាទអ៊ុំចឹងជាចុងក្រោយនឹងខ្ញុំអរគុណច្រើនអ៊ុំដែរបានពិភាក្សាជាមួយខ្ញុំដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ ចឹងហាសអ៊ុំ?

ខ៖ ចា៎!!!នឹងហើយ

ក៖ បាទអរគុណច្រើនអ៊ុំ៕៕៕